**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០២៦/០១/២០១១ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០១១

**ជម្រាបមក**

**ឯកឧត្តម លោកជំទាវ អ្នកតំណាងរាស្ត្រទាំង ១៤រូប**

**កម្មវត្ថុ** : សំណើរបស់ឯកឧត្តម លោកជំទាវ អ្នកតំណាងរាស្ត្រទាំង ១៤រូប សុំឱ្យចាត់វិធានការចំពោះនាយករដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្នុងរាជរដ្ឋាភិបាល ដែលបានបំពានមាត្រា ៩៦ នៃរដ្ឋធម្មនុញ្ញ ដោយមិនឆ្លើយនឹងសំណួររបស់អ្នកតំណាងរាស្ត្រ ដើម្បីធានាការពារការគោរពរដ្ឋធម្មនុញ្ញ ។

**យោង** : លិខិត ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០១១ របស់ឯកឧត្តម លោកជំទាវ អ្នកតំណាងរាស្ត្រទាំង ១៤រូប។

តាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តម លោកជំទាវ មេត្តាជ្រាបថា ក្នុងកិច្ចប្រជុំនាថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០១១ ក្រុមប្រឹក្សាធម្មនុញ្ញ បានពិនិត្យសំណើរបស់ឯកឧត្តម លោកជំទាវ រួចហើយ ។ ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា សំណើសុំចាត់វិធានការចំពោះនាយករដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្នុងរាជរដ្ឋាភិបាល ដែលមិនបានឆ្លើយនឹងសំណួររបស់អ្នកតំណាងរាស្ត្រ មិនចូលក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ។

សូមឯកឧត្តម លោកជំទាវ ទទួលនូវការរាប់អានអំពីខ្ញុំ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**